# សេចក្តីស្រឡាញ់ដែលពេញខ្នាត នោះបណ្តេញសេចក្តីភ័យខ្លាចចេញ

*ដោយ អែលឌើរ អិល ថម តែរី*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

នៅជុំវិញពិភពលោក ពេលមានព្រះវិហារបរិសុទ្ធថ្មីមួយត្រូវបានសាងសង់ឡើង សាសនាចក្របានធ្វើនូវរឿងមួយដែលជាទំនៀមទម្លាប់ដ៏ត្រឹមត្រូវក្នុងសហរដ្ឋអាមេរិក និងកាណាដា ---គឺយើងធ្វើពិធីសម្ពោធមួយ ។ អំឡុងពេលប៉ុន្មានសប្តាហ៍ពីមុនការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធថ្មី យើងបើកទ្វារជាសាធារណៈ ហើយអញ្ជើញអ្នកដឹកនាំក្នុងរដ្ឋាភិបាល និងខាងសាសនា សមាជិកសាសនាចក្រក្នុងមូលដ្ឋាន និងអ្នកកាន់សាសនាផ្សេងទៀត ឲ្យដើរទស្សនាព្រះវិហារបរិសុទ្ធដែលទើបនឹងសាងសង់ថ្មីនោះ ។

ទាំងនេះជាព្រឹត្តិការណ៍ដ៏អស្ចារ្យ ដើម្បីជួយដល់អ្នកដែលមិនស្គាល់សាសនាចក្រយើងរៀនបន្ថែមទៀត ។ មនុស្សស្ទើរតែគ្រប់គ្នាដែលបានទស្សនាព្រះវិហារបរិសុទ្ធថ្មីមួយហើយ បានស្ញប់ស្ញែងដល់ភាពស្រស់ស្អាតនៃអគារនោះទាំងក្នុងទាំងក្រៅ។ ពួកគេសើចសរសើរចំពោះក្បាច់រចនា និងភាពលម្អិតនៃគ្រប់ទ្រង់ទ្រាយនៃព្រះវិហារបរិសុទ្ធ ។ លើសពីនេះទៀត ពួកអ្នកមកទស្សនាជាច្រើនមានអារម្មណ៍មួយដ៏វិសេសវិសាល ពេលពួកគេបាននាំដើរឆ្លងកាត់ព្រះវិហារបរិសុទ្ធដែលមិនទាន់បានឧទ្ទិសឆ្លង ។ ទាំងនេះ ជាការឆ្លើយតបទូទៅនៃអ្នកមកទស្សនាការសម្ពោធរបស់ យើង តែវាមិនទាន់អស់នៅឡើយទេ ។ អ្វីដែលធ្វើឲ្យពួកអ្នកទស្សនាចាប់អារម្មណ៍ជាងអ្វីៗទាំងអស់ នោះគឺពួកសមាជិកសាសនាចក្រដែលពួកគេបានជួបនៅឯការសម្ពោធនោះ ។ ពួកអ្នកមកទស្សនានោះបានមានចំណាប់អារម្មណ៍ជារៀងរហូតចំពោះម្ចាស់កម្មវិធី ដែលជាពួកបរិសុទ្ធថ្ងៃចុងក្រោយ។

សាសនាចក្រកំពុងទទួលបានការចាប់អារម្មណ៍យ៉ាងច្រើននៅជុំវិញពិភពលោកលើសពីមុន ។ សមាជិកនៃប្រព័ន្ធផ្សព្វផ្សាយបានសរសេរ ឬនិយាយពីសាសនាចក្រជារៀងរាល់ថ្ងៃ ដោយរាយការណ៍ពីសកម្មភាពជាច្រើន ។ ការចេញផ្សាយសារព័ត៌មានជាច្រើនដែលលេចធ្លោបំផុតក្នុងសហរដ្ឋអាមេរិកជាទូទៅពិភាក្សាពីសាសនាចក្រ ឬសមាជិក ។ ការពិភាក្សានេះ កំពុងកើតឡើងនៅជុំវិញពិភពលោកផងដែរ ។

សាសនាចក្រក៏បានទាក់ទាញចំណាប់អារម្មណ៍តាមអ៊ិនធើរណែតដែរ ដូចដែលអ្នកដឹងស្រាប់ហើយ វាបានផ្លាស់ប្តូរយ៉ាងខ្លាំងនូវរបៀបដែលមនុស្សទូទៅចែកចាយព័ត៌មាន ។ នៅជុំវិញពិភពលោក គ្រប់ពេលវេលា សាសនាចក្រ និងការបង្រៀននានារបស់ខ្លួនកំពុងតែត្រូវបានគេពិភាក្សាតាមអ៊ិនធើរណែត តាមកំណត់ហេតុបណ្តាញ និងតាមបណ្តាញសង្គម ដោយមនុស្សដែលមិនធ្លាប់សរសេរសារព័ត៌មាន ឬទស្សនាវដ្តីពីមុន ។ ពួកគេកំពុងថតវីដេអូ និងចែកចាយតាមអ៊ិនធើរណែត ។ អ្នកទាំងនេះជាមនុស្សធម្មតា ---ទាំងសមាជិកសាសនាយើង និងសាសនាផ្សេងទៀត ---ដែលកំពុងលើកឡើងពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ការផ្លាស់ប្តូរក្នុងរបៀបដែលយើងប្រាស្រ័យទាក់ទងពន្យល់មួយផ្នែកពីហេតុផលដែលយើង « ជាពួកមរមន » ត្រូវបានគេកត់សម្គាល់ជាងពេលមុន ។ តែសាសនាចក្រក៏កំពុងតែរីកចម្រើន និងដើរឆ្ពោះទៅមុខផងដែរ ។ មានមនុស្សជាច្រើនដែលមានសមាជិកសាសនាចក្រជាអ្នកជិតខាង និងជាមិត្ត ហើយមានសមាជិកសាសនាចក្រដ៏លេចធ្លោក្នុងជួររដ្ឋាភិបាល ជំនួញ កម្មវិធីកម្សាន្ត ផ្នែកអប់រំ និងនៅគ្រប់ទីកន្លែងផ្សេងទៀត ។ សូម្បីតែអ្នកដែលមិនមែនជាសមាជិក ក៏ដឹងពីការណ៍នេះដែរ ហើយងឿងឆ្ងល់ថា តើមានអ្វីកំពុងតែកើតឡើង ។ វាជារឿងដ៏អស្ចារ្យដែលឥឡូវនេះ មានមនុស្សជាច្រើនបានស្គាល់ពីសាសនាចក្រនេះ និងពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ខណៈដែលសាសនាចក្រនេះ កំពុងតែត្រូវបានគេស្គាល់ច្រើន ក៏នៅមានមនុស្សជាច្រើន ដែលមិនទាន់យល់ពីសាសនាចក្រនេះដែរ ។ មានអ្នកខ្លះត្រូវបានគេបង្រៀនឲ្យសង្ស័យចំពោះសាសនាចក្រនេះ ហើយជឿលើទស្សនៈអវិជ្ជមានពីសាសនាចក្រដោយមិនបានសួរពីប្រភព និងសុពលភាពរបស់វាឡើយ ។ ក៏មានការយល់ខុស និងការភាន់ច្រឡំពីសាសនាចក្រ និងពីអ្វីដែលសាសនាចក្រតំណាងឲ្យផងដែរ ។ ការណ៍នេះពិតចាប់តាំងពីសម័យព្យាការីយ៉ូសែប ស៊្មីធ មកម្ល៉េះ ។

យ៉ូសែប ស៊្មីធ បានសរសេរផ្នែកមួយនៃប្រវត្តិលោក « ដើម្បីកែខៃគំនិតមនុស្ស ហើយតម្រង់មនុស្សទាំងអស់ដែលស្វែងរកសេចក្តីពិតចំពោះការពិតត្រង់ » ( យ៉ូសែប ស៊្មីធ---ប្រវត្តិ 1:1) ។វាជាការពិត ដែលថា នឹងមានអ្នកផ្លាស់ប្តូរសេចក្តីពិតនោះ ហើយបង្ហាញការបង្រៀននៃសាសនាចក្រដោយខុសឆ្គងជានិច្ច ។ តែអ្នកដែលចោទសួរពីសាសនាចក្រ គឺភាគច្រើនគ្រាន់តែចង់យល់ដឹងប៉ុណ្ណោះ ។ មនុស្សស្អាតស្អំទាំងនេះ គឺចង់ដឹងពីយើងយ៉ាងខ្លាំង ។

ការបង្ហាញខ្លួន និងកេរ្តិ៍ឈ្មោះដ៏លេចធ្លោនៃសាសនាចក្របង្ហាញពីឱកាសមួយដ៏អស្ចារ្យសម្រាប់យើងក្នុងនាមជាសមាជិក ។ យើងអាចជួយ « កែខៃគំនិតមនុស្ស និងកែតម្រូវព័ត៌មានខុសឆ្គង ពេលយើងត្រូវបានគេពិពណ៌នាបំភ្លើសពីការពិត ។ អ្វីដែលសំខាន់ជាងនេះទៀត គឺយើងអាចចែកចាយថាយើងជានរណា ។

មានរឿងជាច្រើនដែលយើងអាចធ្វើ ---ដែលអ្នកអាចធ្វើ ---ដើម្បីបង្កើនការយល់ដឹងពីសាសនាចក្រ ។ បើយើងធ្វើវាដោយឥរិយាបថដូចគ្នា ហើយប្រព្រឹត្តខ្លួនយើង ដូចដែលយើងបានធ្វើ ពេលយើងធ្វើការសម្ពោធព្រះវិហារបរិសុទ្ធ នោះមិត្ត និងអ្នកជិតខាង នឹងយល់ពីយើងកាន់តែប្រសើរឡើង ។ ការសង្ស័យរបស់គេនឹងរសាយ ទស្សនៈអវិជ្ជមាននឹងរលាយបាត់ ហើយពួកគេនឹងចាប់ផ្តើមយល់ពីលក្ខណៈពិតនៃសាសនាចក្រ ។

ខ្ញុំសូមណែនាំនូវគំនិតមួយចំនួនអំពីអ្វីដែលយើងម្នាក់ៗអាចធ្វើ ។

ទីមួយ យើងត្រូវរឹងមាំក្នុងការប្រកាសរបស់យើងអំពីព្រះយេស៊ូវគ្រីស្ទ ។ យើងចង់ឲ្យអ្នកដទៃដឹងថា យើងជឿថាទ្រង់ជាអង្គដ៏សំខាន់បំផុតក្នុងប្រវត្តិសាស្រ្តមនុស្សលោក ។ ឆាកជីវិត និងការបង្រៀនទ្រង់ជាសារលិខិតដ៏សំខាន់ក្នុងព្រះគម្ពីរប៊ីប និងព្រះគម្ពីរផ្សេងទៀត ដែលយើងចាត់ទុកថាជាព្រះគម្ពីរបរិសុទ្ធ ។ ព្រះគម្ពីរសញ្ញាចាស់ បានប្រាប់យើងពីការបម្រើមុនឆាកជីវិតនេះរបស់ព្រះគ្រីស្ទ ។ ព្រះគម្ពីរសញ្ញាថ្មីរៀបរាប់ពីការបម្រើរបស់ទ្រង់លើផែនដី ។ ព្រះគម្ពីរមរមនផ្តល់ជាសាក្សីទីពីរដល់យើងនៃការបម្រើរបស់ទ្រង់លើផែនដី ។

ទ្រង់យាងមកផែនដីដើម្បីប្រកាសពីដំណឹងល្អទ្រង់ដែលជាគ្រឹះមួយសម្រាប់មនុស្សលោក ដើម្បីឲ្យកូនចៅទាំងអស់របស់ព្រះអាចរៀន និងធ្វើតាមការបង្រៀនទ្រង់ ។ រួចហើយទ្រង់បានលះបង់ព្រះជន្មទ្រង់ ដើម្បីធ្វើជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះយើង ។ មានតែតាមរយៈព្រះគ្រីស្ទប៉ុណ្ណោះទើបសេចក្តី សង្គ្រោះយើងអាចកើតមានបាន ។ នេះជាហេតុផលដែលយើងជឿថាទ្រង់ជាអង្គដ៏សំខាន់បំផុតក្នុងប្រវត្តិសាស្រ្តមនុស្សលោក ។ ជោគវាសនាដ៏អស់កល្បរបស់យើងគឺស្ថិតក្នុងព្រះហស្តទ្រង់ជានិច្ច ។ វាជារឿងមួយដ៏មោទនភាពដើម្បីជឿលើទ្រង់ ហើយទទួលយកទ្រង់ជាព្រះអង្គសង្គ្រោះជាព្រះអម្ចាស់ និងជាចៅហ្វាយយើង ។

យើងក៏ជឿថា ការស្វែងរកក្តីរីករាយ ក្តីសង្ឃឹម និងសុភមង្គលដ៏ធំធេងបំផុត អាចកើតមានតែតាមរយៈព្រះគ្រីស្ទប៉ុណ្ណោះ ---ទាំងក្នុងជីវិតនេះ និងក្នុងភាពអស់កល្ប ។ គោលលទ្ធិយើង ដូចដែលបានបង្រៀនក្នុងព្រះគម្ពីរមរមន បានចែងយ៉ាងច្បាស់ថា ៖ « ហេតុដូច្នោះហើយ អ្នករាល់គ្នាត្រូវតែឈានទៅមុខដោយខ្ជាប់ខ្លួននៅក្នុងព្រះគ្រីស្ទ ដោយមានការភ្លឺថ្លានៃសេចក្តីសង្ឃឹមដ៏ឥតខ្ចោះ ហើយដោយមានចិត្តស្រឡាញ់ព្រះ និងមនុស្សគ្រប់រូប ។ ហេតុដូច្នោះហើយ បើសិនជាអ្នករាល់គ្នាខិតខំជឿនទៅមុខដោយទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត មើលចុះ នោះព្រះវរបិតា ទ្រង់មានព្រះបន្ទូលដូច្នេះថា ៖ អ្នករាល់គ្នានឹងមានជីវិតដ៏នៅអស់កល្បជានិច្ច » ( នីហ្វៃទី2 31:20 ) ។

យើងប្រកាសពីជំនឿយើងលើព្រះយេស៊ូវគ្រីស្ទ ហើយទទួលយកទ្រង់ជាព្រះអង្គសង្គ្រោះយើង ។ ទ្រង់នឹងប្រទានពរ ហើយដឹកនាំយើងក្នុងគ្រប់កិច្ចការរបស់យើង ។ ពេលយើងធ្វើការក្នុងជីវិតរមែងស្លាប់នេះ ទ្រង់នឹងពង្រឹងយើង ហើយនាំក្តីសុខសាន្តឲ្យកើតមានដល់យើងក្នុងគ្រានៃការសាកល្បង ។ សមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដើរដោយសេចក្តីជំនឿចំពោះទ្រង់ ដែលជាម្ចាស់នៃសាសនាចក្រនេះ ។

ទីពីរ សូមធ្វើជាគំរូដ៏សុចរិតមួយដល់អ្នកដទៃ ។ បន្ទាប់ពីការប្រកាសពីជំនឿយើងមក យើងត្រូវតែធ្វើតាមពាក្យទូន្មានដែលបានផ្តល់ឲ្យយើងក្នុងធីម៉ូថេទី1 4:12 ថា ៖ « ចូរធ្វើជាគំរូដល់ពួកអ្នកជឿ ដោយពាក្យសម្តី កិរិយាប្រព្រឹត្ត សេចក្តីស្រឡាញ់ សេចក្តីជំនឿ និងសេចក្តីបរិសុទ្ធ » ។

ព្រះអង្គសង្គ្រោះបានបង្រៀនពីសារៈសំខាន់នៃការធ្វើជាគំរូពីសេចក្តីជំនឿដល់យើង ដោយមានបន្ទូលថា « ចូរឲ្យពន្លឺរបស់អ្នករាល់គ្នាបានភ្លឺនៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អដែលអ្នករាល់គ្នាប្រព្រឹត្ត រួចសរសើរដំកើងដល់ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌ » ( ម៉ាថាយ 5:16 ) ។

ជីវិតយើងគប្បីធ្វើជាគំរូនៃការល្អ និងគុណធម៌ ដល់ពិភពលោកនេះ ពេលយើងព្យាយាមដើរតាមគំរូរបស់ទ្រង់។ កិច្ចការល្អនៃយើងម្នាក់ៗអាចបង្កើនកិត្តិនាមដល់ព្រះអង្គសង្គ្រោះ និងសាសនាចក្រទ្រង់ ។ ពេលយើងចូលរួមក្នុងកិច្ចការល្អ ដោយធ្វើជាបុរស និងស្រ្តីថ្លៃថ្នូរ ហើយសុចរិត នោះពន្លឺនៃព្រះគ្រីស្ទនឹងត្រូវបានបង្ហាញនៅក្នុងជីវិតយើង ។

បន្ទាប់ទៀត សូមនិយាយគាំទ្រដល់សាសនាចក្រ ។ ក្នុងបុព្វហេតុនៃជីវិតប្រចាំថ្ងៃយើង យើងត្រូវបានប្រទានពរជាមួយនឹងឱកាស ដើម្បីចែកចាយពីអ្វីដែលយើងជឿដល់អ្នកដទៃ ។ ពេលប្រាស្រ័យទាក់ទងផ្ទាល់ខ្លួន និងខាងអាជីព យើងត្រូវការជំនឿសាសនាយើង នោះពួកគេនឹងអញ្ជើញយើងឲ្យចែកចាយថា យើងជានរណា និងអ្វីដែលយើងជឿ ។ ពួកគេអាចចាប់អារម្មណ៍ ឬមិនចាប់អារម្មណ៍ក៏ថាបាន តែពួកគេបានចាប់អារម្មណ៍ចង់ដឹងពីយើងក្នុងកម្រិតដ៏ស៊ីជម្រៅមួយ ។

ការណែនាំរបស់ខ្ញុំសម្រាប់អ្នក គឺទទួលយកការអញ្ជើញពួកគេ ។ មិត្តភ័ក្តិអ្នកមិនបានអញ្ជើញអ្នកឲ្យទៅបង្រៀន ផ្សាយ ពន្យល់ និងទូន្មាននោះឡើយ ។ សូមស្និទ្ធស្នាលនឹងពួកគេតាមរបៀបសន្ទនាទៅវិញទៅមក ---ចែកចាយអ្វីមួយពីជំនឿសាសនាអ្នក តែក៏សូមសួរពីជំនឿរបស់ពួកគេដែរ ។ សូមវិភាគពីកម្រិតនៃការចាប់អារម្មណ៍របស់គេដោយសួរសំនួរដល់ពួកគេ ។ បើពួកគេមានសំនួរច្រើន សូមផ្តោតការសន្ទនាលើការឆ្លើយសំនួរពួកគេ ។ សូមចងចាំជានិច្ចថា វាប្រសើរបើពួកគេសួរ ជាជាងអ្នកប្រាប់គេ ។

មានសមាជិកមួយចំនួនហាក់ដូចជាចង់រក្សាភាពជាសមាជិករបស់ខ្លួនក្នុងសាសនាចក្រជាការសម្ងាត់ ។ ពួកគេមានហេតុផលរបស់គេ ។ឧទាហរណ៍ ពួកគេអាចជឿថាវាពុំមែនជាកន្លែងដែលពួកគេត្រូវចែកចាយជំនឿរបស់ខ្លួន ។ ប្រហែលជាពួកគេភ័យខ្លាចថា ពួកគេអាចនឹងធ្វើនូវកំហុសមួយ ឬសួរសំ-នួរដែលពួកគេមិនអាចឆ្លើយបាន ។បើគំនិតបែបនោះធ្លាប់កើតមានចំពោះអ្នក នោះខ្ញុំមានការណែនាំមួយចំនួនសម្រាប់អ្នក ។ គ្រាន់តែចងចាំនូវពាក្យរបស់យ៉ូហានថា ៖ « គ្មានសេចក្តីភ័យខ្លាចណានៅក្នុងសេចក្តីស្រឡាញ់ឡើយ សេចក្តីស្រឡាញ់ដែលពេញខ្នាត នោះបណ្តេញសេចក្តីភ័យខ្លាចចេញ » ( យ៉ូហានទី1 4:18 ) ។ បើយើងគ្រាន់តែស្រឡាញ់ព្រះ ហើយស្រឡាញ់អ្នកជិតខាងយើង នោះយើងត្រូវបានសន្យាថា យើងនឹងយកឈ្នះលើការភ័យខ្លាចរបស់យើង ។

បើអ្នកបានចូលទៅ www.mormon.org ថ្មីៗនេះ ជាវិបសាយរបស់សាសនាចក្រសម្រាប់អ្នកដែលមានចំណាប់អារម្មណ៍ក្នុងការរៀនពីសាសនាចក្រ នោះអ្នកនឹងឃើញមានសមាជិកដែលបានចែកចាយព័ត៌មានរបស់ពួកគេ ។ពួកគេបានបង្កើតទម្រង់លើអ៊ិនធើរណែត ដែលពន្យល់ថាពួកគេជានរណា និងពីហេតុផលដែលជំនឿសាសនារបស់ពួកគេមានសារៈសំខាន់ចំពោះពួកគេ ។ ពួកគេកំពុងពិភាក្សាពីសេចក្តីជំនឿរបស់គេ ។

របៀបដែលយើងនិយាយពីសាសនាចក្រគឺសំខាន់ដូចគ្នានឹងអ្វីដែលយើងនិយាយ ។ យើងគប្បីចាប់ផ្តើមការសន្ទនាបែបនេះដោយក្តីស្រឡាញ់ដូចជាព្រះគ្រីស្ទ ។សម្លេងយើង មិនថាដោយការនិយាយ ឬការសរសេរនោះទេ គប្បីមានការគោរព និងរាបសា ចំពោះការឆ្លើយតបពីអ្នកដទៃ ។ យើងគប្បីមានភាពស្មោះត្រង់ ហើយបើកទូលាយ និងព្យាយាមធ្វើឲ្យមានភាពច្បាស់លាស់ចំពោះអ្វីដែលយើងនិយាយ ។ យើងចង់ចៀសវាងពីការធ្វើឲ្យអាក់អន់ចិត្ត ឬការមិនយល់ស្រប ។ សាវកពេត្រុសបានពន្យល់ថា « តែចូរឲ្យអ្នករាល់គ្នាបានបរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់ ដូចជាព្រះ ដែលហៅអ្នករាល់គ្នាទ្រង់បរិសុទ្ធដែរ »     ( ពេត្រុសទី1 1:15 ) ។

« របៀបសន្ទនា » សព្វថ្ងៃនេះ ហាក់ដូចជាមានច្រើនឡើងៗនៅតាម អ៊ិនធើរណែត ។ យើងសូមលើកទឹកចិត្តមនុស្សទាំងអស់ ទាំងចាស់ទាំងក្មេងឲ្យប្រើ អ៊ិនធើរណែត និងបណ្តាញសង្គមនានា ដើម្បីជួយ និងចែកចាយពីជំនឿសាសនាខ្លួន ។

ពេលអ្នកប្រើ អ៊ិនធើរណែត អ្នកអាចមើលឃើញនូវការសន្ទនាបន្តបន្ទាប់ពីសាសនាចក្រនេះ ។ ពេលបានដឹកនាំពីព្រះវិញ្ញាណ សូមកុំស្ទាក់ស្ទើរបន្ថែមយោបល់អ្នកក្នុងការសន្ទនាទាំងនេះ ។

សារលិខិតនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ គឺមិនដូចជាអ្វីផ្សេងទៀតដែលអ្នកធ្លាប់ចែកចាយនឹងអ្នកដទៃឡើយ ។ ក្នុងគ្រាដែលមានប្រភពព័ត៌មានផ្សេងៗគ្នា នេះគឺជាព័ត៌មានដ៏មានតម្លៃបំផុតក្នុងពិភពលោកនេះ ។ ពុំមានការចោទសួរពីតម្លៃរបស់វាឡើយ ។ វាគឺជាមុក្តាដ៏មានតម្លៃ ( សូមម៉ាថាយ 13:46 ) ។

ពេលនិយាយពីសាសនាចក្រ យើងមិនត្រូវព្យាយាមធ្វើឲ្យល្អហួសពីការពិតនោះទេ ។ យើងមិនចាំបាច់បង្វែរនូវសារលិខិតយើងឡើយ ។ យើងត្រូវនិយាយពីសារលិខិតនោះដោយស្មោះ និងដោយត្រង់ៗ ។ បើយើងនឹងចាប់ផ្តើមនូវការពិភាក្សា នោះសារលិខិតនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ នឹងបង្ហាញឲ្យឃើញដល់អស់អ្នកណាដែលត្រូវបានរៀបចំឲ្យទទួលវាដោយខ្លួនឯង ។

ពេលខ្លះ មានការខុសប្លែកគ្នាដ៏ធំមួយ ---ការខុសប្លែកដ៏ធំមួយក្នុងការយល់ដឹង ---រវាងរបៀបដែលពិសោធន៍សាសនាចក្រពីខាងក្នុង និងពីរបៀបដែលអ្នកដទៃមើលឃើញពីខាងក្រៅ ។ នេះជាហេតុផលដ៏សំខាន់ដែលយើងធ្វើការសម្ពោធព្រះវិហារបរិសុទ្ធឡើង ពីមុនព្រះវិហារបរិសុទ្ធថ្មីនីមួយៗ ត្រូវបាន

ឧទ្ទិសឆ្លង ។ សមាជិកស្ម័គ្រចិត្តនៅឯការសម្ពោធព្រះវិហារបរិសុទ្ធ គឺគ្រាន់តែព្យាយាមជួយមនុស្សដទៃទៀតឲ្យមើលឃើញសាសនាចក្រ ដូចជាពួកគេបានឃើញពីខាងក្នុងដែរ ។ ពួកគេដឹងថា សាសនាចក្រ មានកិច្ចការមួយយ៉ាងអស្ចារ្យ ហើយចម្លែក ហើយពួកគេចង់ឲ្យមនុស្សដទៃទៀត ដឹងពីការណ៍នេះដែរ ។ ខ្ញុំសូមឲ្យអ្នករាល់គ្នា ម្នាក់ៗធ្វើដូចគ្នានេះដែរ ។

ខ្ញុំសូមសន្យានឹងអ្នកថា បើអ្នកនឹងឆ្លើយតបចំពោះការអញ្ជើញឲ្យចែកចាយជំនឿ និងអារម្មណ៍អ្នកពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលបានស្ដារឡើងវិញ នោះវិញ្ញាណនៃក្ដីស្រឡាញ់ និងវិញ្ញាណនៃការលើកទឹកចិត្ត នឹងក្លាយជាដៃគូដ៏ខ្ជាប់ខ្ជួនរបស់អ្នក ត្បិត « សេចក្ដីស្រឡាញ់ដែលពេញខ្នាត នោះបណ្ដេញសេចក្ដីភ័យខ្លាចចេញ » ( យ៉ូហានទី1 4:18 ) ។
នេះជាពេលនៃឱកាសដ៏ធំដើម្បីចែកចាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាមួយនឹងអ្នកដទៃ ។ សូមឲ្យយើងរៀបចំខ្លួនដើម្បីក្ដាប់ឱកាសដែលយើងម្នាក់ៗមាន ដើម្បីចែកចាយពីជំនឿរបស់យើង ខ្ញុំសូមអធិស្ឋានដោយរាបសាក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។